**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
អគ្គស្នងការដ្ឋាននគរបាលជាតិ
ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
លេខ ១៤៨ សជណ

# ជម្រាបជូន

## លោកប្រធានតុលាការក្រុងភ្នំពេញ

## លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

**កម្មវត្ថុ:** ស្តីពីការបញ្ជូនដីកាកោះ ដីកាអញ្ជើញ ដីកាបង្គាប់អោយចូលខ្លួន ដីកានាំខ្លួន និងដីកាចាប់ខ្លួន ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានតុលាការ លោកព្រះរាជអាជ្ញាជ្រាបថា

ដើម្បីសម្រួលដល់ការងាររបស់តុលាកា និងដើម្បីចៀសវាងភាពយឺតយ៉ាវក្នុងការអនុវត្តដីកា ខ្ញុំសូមលោកប្រធានតុលាកា និងលោកព្រះរាជអាជ្ញាផ្ញើរដីកាកោះ ដីកអញ្ជើញ និងដីកាបង្គាប់អោយចូលខ្លួន ទៅផ្ទាល់ដល់សាមីខ្លួន ឬតាមរយៈមន្ត្រីនគរបាលមូលដ្ឋាន( ដូចជាអធិការដ្ឋាននគរបាលខណ្ឌ ប៉ុស្តិ៍នគរបាលរដ្ឋបាល )តែម្តងចុះ ដោយពុំចាំបាច់ឆ្លងកាត់ការិយាល័យកណ្តាលនគរបាលយុត្តិធម៌ ឬ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញទៀតឡើយ ។ ដោយឡែកដីកានាំខ្លួន និងដីកាចាប់ខ្លួន ត្រូវអនុវត្តផ្ញើរមកការិយាល័យកណ្តាលនគរបាលយុត្តិធម៌ ដើម្បីអនុវត្តតាមលំនាំមុនដដែល ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក ប្រធានតុលាការ ក្រុងភ្នំពេញ និងលោកព្រះរាជអាជ្ញាជ្រាប ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥

**ស្នងការនគរបាលរាជធានីភ្នំពេញ**

ឧត្តមសេនីយ៍ត្រី **ហេង ពៅ**

<u>ចម្លងជូន</u>
-ការិយាល័យកណ្តាលនគរបាលយុត្តិធម៌
-អធិការដ្ឋាននគរបាលខណ្ឌទាំង៧
( ដើម្បីអនុវត្ត )